00542258

លេខ/No: D337/7

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
# OFFICE OF THE CO-INVESTIGATING JUDGES
# BUREAU DES CO-JUGES D'INSTRUCTION

## អនុស្សរណៈអន្តរការិយាល័យ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 06 / 2010
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ជូនចំពោះ៖** មេធាវី និងអន្តរការីនៃដើមបណ្តឹងរដ្ឋប្បវេណី

ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

**តាមរយៈ៖** លោកជំទាវ Helen Jarvis
លោក Paul Oertly
**អង្គភាពគាំពារជនរងគ្រោះ**

**ចម្លងជូន៖** ការិយាល័យរដ្ឋបាល

**ពី៖** ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel Lemonde
សហចៅក្រមស៊ើបអង្កេត

**កម្មវត្ថុ៖** **ការតំណាងតាមផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី**

កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានប្រកាសពីគោលបំណងរបស់ខ្លួនក្នុងការចេញដីកាមួយ នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០១០ ចាត់តាំងមេធាវីសម្រាប់ដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលមិនទាន់មានតំណាងនៅពេលនោះ[1]។

---

[1] D337/6 អនុស្សរណៈអន្តរការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាពេលវេលាកំណត់សម្រាប់ដាក់ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទំព័រ ២

ដីកានោះមិនទាន់បានចេញនៅឡើយ ពីព្រោះត្រូវឲ្យមានការជ្រើសរើសមេធាវីបន្ថែមជាមុនសិនដោយការិយាល័យរដ្ឋបាល។ ការជ្រើសរើសនៅកំពុងតែដំណើរការ ប៉ុន្តែរហូតមកទល់ពេលនេះ មេធាវីទាំងនេះ មិនទាន់បានជ្រើសរើសនៅឡើយ។

ដោយអនុវត្តតាមវិធាន ២៣ ស្ទួនពីរ (២)(ក) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលត្រូវបានធ្វើវិសោធនកម្ម នៅក្នុងកិច្ចប្រជុំពេញអង្គលើកចុងក្រោយ *“រាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានតំណាងដោយមេធាវី យ៉ាងយូរបំផុតត្រឹមពេលចេញដីកាដំណោះស្រាយ”* និង *“សហចៅក្រមស៊ើបអង្កេត ត្រូវ (...) ចេញដីកាដែលសមស្រប សម្រាប់គោលដៅនេះ”*។

ដីកាខាងលើ នឹងត្រូវចេញឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។